ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍
លេខ:.....០..៦៧...គសអ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតលេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍

### គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញសេចក្តីសម្រេចលេខ ៩៥ សសរ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការបោះឆ្នោត
- យោងការងារចាំបាច់របស់គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍

### ស ម្រេ ច

**ប្រការ ១ :** បង្កើតលេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ដែលមានសមាសភាពដូចតទៅ ៖

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម នាយឧត្តមសេនីយ៍ | ហុក ឡុងឌី | អគ្គស្នងការនគរបាលជាតិ | ប្រធាន |
| ២- | ឯកឧត្តម នាយឧត្តមសេនីយ៍ | មាស សុភា | អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងទ័ពជើងគោក | អនុប្រធាន |



www.pheakdeylaw.com

| | | | | |
|---|---|---|---|---|
| ៣- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ខៀវ សុភ័គ | អគ្គលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៤- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ជា តារា | នាយរងសេនាធិការចម្រុះ និងជា នាយកទីចាត់ការកលយុទ្ធ | សមាជិក |
| ៥- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ជា សារិន | នាយសេនាធិការកងទ័ពជើងគោក | សមាជិក |
| ៦- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | នេត សាវឿន | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៧- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | យូ ស៊ុនឡុង | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៨- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ម៉ៅ ច័ន្ទតារា | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៩- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | សុខ ផល | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ១០- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | គន្ធ សំអឿន | ប្រធាននាយកដ្ឋានកណ្តាល សន្តិសុខ | សមាជិក |
| ១១- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ចាន់ អ៊ែន | ប្រធាននាយកដ្ឋានកណ្តាល នគរបាលព្រំដែន | សមាជិក |
| ១២- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | អ៊ុក គឹមលេខ | ប្រធាននាយកដ្ឋានកណ្តាល សណ្តាប់ធ្នាប់សាធារណៈ | សមាជិក |
| ១៣- | ឯកឧត្តម ឧត្តមសេនីយ៍ទោ | គង់ មុន្នី | មេបញ្ជាការរងកងទ័ពអាកាស | សមាជិក |
| ១៤- | ឯកឧត្តម ឧត្តមនាវីទោ | មាស ថន | មេបញ្ជាការរងកងទ័ពជើងទឹក | សមាជិក |
| ១៥- | ឯកឧត្តម ឧត្តមសេនីយ៍ទោ | ទ័ាន់ ណយ | ប្រធាននាយកដ្ឋានកណ្តាល នគរបាលយុត្តិធម៌ | សមាជិក |
| ១៦- | ឯកឧត្តម ឧត្តមសេនីយ៍ទោ | អៅ គឹមឈួន | ប្រធាននាយកដ្ឋានកណ្តាល មធ្យោបាយ | សមាជិក |
| ១៧- | លោក ឧត្តមសេនីយ៍ត្រី | គៀត ច័ន្ទថារិទ្ធ | ប្រធានសេនាធិការដ្ឋាន នៃ អគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៨- | លោក ឧត្តមសេនីយ៍ត្រី | ភួង ស៊ុំគិន | នាយរងសេនាធិការកងរាជ អាវុធហត្ថ | សមាជិក |
| ១៩- | លោក ឧត្តមសេនីយ៍ត្រី | ម៉ិត គឹមហុង | ប្រធាននាយកដ្ឋានប្រឆាំង ភេរវកម្ម | សមាជិក |
| ២០- | លោក ឧត្តមសេនីយ៍ត្រី | រ៉ៃ ស៊ុណារិទ្ធ | ប្រធាននាយកដ្ឋានព័ត៌មានទូទៅ | សមាជិក |
| ២១- | លោក ឧត្តមសេនីយ៍ត្រី | ម៉ក់ ជីតូ | ប្រធាននាយកដ្ឋាននគរបាល ព្រហ្មទណ្ឌ | សមាជិក |
| ២២- | លោក ឧត្តមសេនីយ៍ត្រី | ទ័ាន់ វដ្ឋា | ប្រធាននាយកដ្ឋាននគរបាល បច្ចេកទេសវិទ្យាសាស្ត្រ | សមាជិក |

www.pheakdeylaw.com

២៣- លោក ឧត្តមសេនីយ៍ត្រី ឯម សំណាង ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

២៤- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

ប្រការ ២ : លេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ មានភារកិច្ចដូចតទៅ ៖

- ជួយប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ក្នុងការផ្សព្វផ្សាយ តាមដាន និងចាត់តាំងអនុវត្តផែនការស្តីពីកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២ ឆ្នាំ២០០៧ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៤ ឆ្នាំ២០០៨ ។
- ផ្សព្វផ្សាយផែនការ បទបញ្ជា និងសេចក្តីណែនាំផ្សេងៗ របស់គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ទៅគណៈបញ្ជាការឯកភាពគ្រប់លំដាប់ថ្នាក់ ។
- ចាត់តាំងកម្លាំង ដើម្បីប្រតិបត្តិការការពារការបោះឆ្នោត តាមផែនការដែលបានកំណត់ ។
- ប្រមូលផ្តុំពត៌មានពីគណៈបញ្ជាការឯកភាពគ្រប់លំដាប់ថ្នាក់ ដើម្បីរាយការណ៍ជូនប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ។
- ពិនិត្យដោះស្រាយរាល់វិវាទផ្សេងៗ ឬបញ្ហាំងតវ៉ាពាក់ព័ន្ធដល់សន្តិសុខសម្រាប់ការបោះឆ្នោត ធ្វើរបាយការណ៍ ជូនគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ រៀងរាល់ ១៥ ថ្ងៃម្តង ។
- រៀបចំកិច្ចប្រជុំ និងធ្វើលិខិតអញ្ជើញគ្រប់សមាជិក នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ទាំងអស់ តាមការសម្រេចរបស់ប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ។
- ធ្វើគម្រោងថវិកា ឧបករណ៍ សម្ភារៈ មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ សម្រាប់បម្រើការងារបោះឆ្នោតទាំងពីរលើក ដាក់ជូនប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ពិនិត្យសម្រេច ។
- ប្រមូលផ្តុំ ចាត់ចែង ប្រើប្រាស់សម្ភារៈ ឧបករណ៍ និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទរបស់បណ្តាអង្គភាពផ្ទាល់ដែលមានស្រាប់ ដើម្បីបម្រើប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ឱ្យបានល្អប្រសើរ ក្នុងរយៈពេលនៃដំណើរការរៀបចំការបោះឆ្នោតទាំងពីរលើក ។
- ចាត់ចែងផ្តល់ថវិកាបំប៉នជូនកម្លាំងការពារតាមគោលដៅ និងធ្វើគម្រោងបែងចែកនូវឧបករណ៍ សម្ភារៈ និងមធ្យោបាយផ្សេងៗឱ្យបានសមស្របទៅតាមមុខសញ្ញា និងគោលដៅចាំបាច់ ។
- ធ្វើរបាយការណ៍ចំណូល ចំណាយថវិកា និងប្រើប្រាស់ឧបករណ៍ សម្ភារៈ និងមធ្យោបាយគ្រប់ប្រភេទប្រចាំខែ ជូនគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល ។
- ផ្សព្វផ្សាយនៅក្នុង និងទៅក្រៅប្រទេស នូវពត៌មានទាំងឡាយណាដែលពិនិត្យឃើញថា ចាំបាច់ត្រូវជូនដល់សាធារណមតិជាតិ និងអន្តរជាតិ បានជ្រាប ។

www.pheakdeylaw.com

**ប្រការ ៣ :** ក្នុងករណីចាំបាច់ លេខាធិការដ្ឋានអាចស្នើសុំទៅគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ បង្កើតក្រុមការងារជាជំនួយការក្នុងការតាមដាន ដឹកនាំបញ្ជា និងកិច្ចការរដ្ឋបាល ។ លេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ និងសមាសភាពដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៧

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជា

ប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍

ស ខេង

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប
- អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- គ្រប់គណៈបញ្ជាការឯកភាពខេត្ត ក្រុង
- ដូចប្រការ ១
- ឯកសារ កាលប្បវត្តិ

ជ

www.pheakdeylaw.com